Mekong Migration Network (MMN)

# ការធ្វើចំណាកស្រុកនៅក្នុងមហាអនុតំបន់មេគង្គ

## ឯកសារ : ការសិក្សាស្រាវជ្រាវស្តីពី ការឃាត់ខ្លួន ការឃុំខ្លួន និងចាប់ខ្លួនបញ្ជូនត្រលប់មកវិញ

ឯកសារស្រាវជ្រាវលើកទី ០៣ ដែលរៀបរាងឡើងដោយបណ្តាញចំណាកស្រុកមេគង្គ បានលើកឡើងនៅបញ្ហា ដែលមិនត្រឹមតែពាក់ពន្ធ័ទៅនិងភាពស្របច្បាប់នៃនីតិវិធី ដែលត្រូវបានគេអនុវត្តប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានលើកឡើង ពីនិយ័តកម្ម ដែលមានលក្ខណះសមហេតុផលនៅក្នុង ការឃាត់ខ្លួន ឃុំខ្លួន និងចាប់បញ្ជូនត្រលប់មកវិញ នៃជនចំណាកស្រុកនៅក្នុងអនុតំបន់មេគង្គផងដែរ ។ ឯកសារនេះគឺជាលទ្ធផលនៃការសិក្សារស្រាវជ្រាវរួមគ្នា រវាង សមាគមជនចំណាកស្រុក អង្គការសង្គមស៊ីវិល បណ្តាញសារព័ត៌មាន និងវិទ្យាស្ថាននានា ដែលមានមូលដ្ឋាននៅក្នុងប្រទេស ភូមា កម្ពុជា ឡាវ ថៃ វៀតណាម និងប្រទេសចិន ។

ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងការរំលោភបំពានផ្នែកសិទ្ធិមនុស្ស ដែលជនចំណាកស្រុកបានជួបប្រទះ ក្នុងពេលដែលពួកគេត្រូវបានឃាត់ខ្លួន ឃុំខ្លួន និងការចាប់បញ្ជូនត្រលប់មកវិញនោះ របាយការណ៍នេះ នឹងជំរុញដល់បណ្តារដ្ឋាភិបាលនានាដើម្បី :

- បញ្ឈប់ការផ្តន្ទាទោសជនចំណាកស្រុក
- លុបបំបាត់នៅការហាមប្រាមនានា ដែលជាមូលហេតុធ្វើអោយជនចំណាកស្រុកធ្លាក់ខ្លួនទៅក្នុងលក្ខខណ្ឌការងារ ដែលមានលក្ខណៈរំលោភបំពាន និងកេងប្រវ័ញ្ច ហើយក៏ជាមូលហេតុ ដែលធ្វើអោយពួកគេប្រឈមមុខនឹងការឃាត់ខ្លួន ឃុំខ្លួន និងការចាប់ខ្លួនបញ្ជូនត្រលប់មកវិញ និង
- ធ្វើការកែទម្រង់នីតិវិធីនៅក្នុងការឃាត់ខ្លួន ឃុំខ្លួន និងការចាប់បញ្ជូនត្រលប់មកវិញ ដើម្បីធានាថា នីតិវិធីទាំងនោះមានលក្ខណៈមនុស្សធម៌ តម្លាភាព និងស្ថិតនៅក្រោមបទបញ្ញត្តិច្បាប់

**www.mekongmigration.org**

**MMN Secretariat**
Hong Kong Office
info@mekongmigration.org
c/o Asian Migrant Centre, Flat 6, 13/F, Block A, Fuk Keung Industrial Building, 66-68 Tong Mi Road, Prince Edward, Kowloon, Hong Kong
Chiang Mai Office
advocacy@mekongmigration.org
c/o MAP Foundation, 63/31 Moo 8, U-mong, Soi 4 (P.O. Box 153 Chiang Mai University 50200) , Thailand

## <u>**ការផ្តន្ទាទោសជនចំណាកស្រុក**</u>

តាមលទ្ធលផនៃការសិក្សារស្រាវជ្រាវបានបង្ហាញអោយឃើញថា ដោយសារតែកង្វះខាតយន្តការដើម្បីធ្វើចំណាកស្រុកស្របច្បាប់នៅក្នុងអនុតំបន់មេគង្គ បានបង្ខំអោយជនចំណាកស្រុក ធ្វើចំណាកស្រុកឆ្លងដែន ដោយខុសច្បាប់ ហើយវាបានបង្កអោយមានគ្រោះថ្នាក់ដល់ជីវិតរបស់ពួកគេ ។ ជីវិតរបស់ជនចំណាកស្រុកស្ថិតនៅកន្លែង ដែលមានគ្រោះថ្នាក់បំផុតនៅពេលដែលពួកគេត្រូវតែ ប្រើប្រាស់នៅមធ្យោបាយលួចលាក់ដើម្បីធ្វើចំណាកស្រុក ដូចជា ការលាក់ខ្លួននៅក្នុងរថយន្តដឹកទំនិញ ជិះទូកតូចៗឆ្លងកាត់សមុទ្រ ការធ្វើដំណើរឆ្លងកាត់ព្រំដែន ដែលពោពេញទៅដោយចំការមីនជាដើម ។ ជាងនេះទៅទៀត ការផ្តន្ទាទោសជនចំណាកស្រុកទាំងនេះ បានផ្តល់ឱកាសដល់មេខ្យល់ធ្វើការបោកបញ្ឆោត និងកេងប្រវញ្ច័ដល់ជនចំណាកស្រុក និងកាន់តែធ្វើអោយមន្ត្រីរដ្ឋាភិបាលដែលពុករលួយធ្វើការគំរាមកំហែងដើម្បីទទួលសំណូកទៀតផង ។

បណ្តាញចំណាកស្រុកមេគង្គសូមផ្តល់អនុសាសន៏ថា បណ្តារដ្ឋាភិបាលនៃមហាអនុតំបន់ទន្លេមេគង្គ គួរតែផ្តល់នូវយន្តការ ដែលសមស្របសំរាប់ប្រជាពលរដ្ឋទាំងអស់ធ្វើចំណាកស្រុកដោយស្របច្បាប់ក្នុងគោលបំណងស្វែងរកការងារធ្វើ និង ស្នើសុំដល់បណ្តារដ្ឋាភិបាល ដែលពាក់ពន្ធ័ផងដែរថា ជនចំណាកស្រុក ដែលបានចូលមកក្នុងប្រទេសរបស់ខ្លួន ដោយគ្មានឯកសារត្រឹមត្រូវ នឹងត្រូវទទួលបាននូវការផ្តល់ជូនឯកសារស្របច្បាប់តាមលក្ខណៈមួយ ដែលសាមញ្ញនៅព្រំដែន។ ប្រសិនបើជនចំណាកស្រុកអាចទទួលបាននូវសេវាកម្មជ្រើសរើសដែលមានលក្ខណៈផ្លូវការ និងស្របច្បាប់នៅតាមព្រំដែន នោះពួកគេអាចធ្វើដំណើរដោយស្របច្បាប់ នឹងដោយចំហរទៅកាន់ទីកន្លែងបំរើការងាររបស់ពួកគេ និងអាចជៀសវាងនៅតំរូវការដែលមានលក្ខណៈគ្រោះថ្នាក់ដល់ជីវិត ដោយសារការប្រើប្រាស់នូវការដឹកជញ្ជូនដែលមានលក្ខណៈខុសច្បាប់។

របាយការនេះក៏បានបង្ហាញអោយឃើញផងដែរថា បន្ទាប់ពីបានមកដល់គោលដៅ ដោយសារការអនុវត្តន៏ច្បាប់មានលក្ខណៈខុសគ្នាបានបង្កើតអោយមានបរិយាកាសនៃការបាត់បង់ទំនុកចិត្ត ការបែកបាក់ និងការអាក់អន់ចិត្តជាដើម។ ខណៈពេលដែលជនចំណាកស្រុកត្រូវបានផ្តន្ទាទោស ដោយសារតែពួកគេមិនបានចុះឈ្មោះដើម្បីទទួលបាននូវលិខិតអនុញ្ញាតអោយធ្វើការងារ ឬ ដោយសារតែពួកគេមិនដាក់លិខិតនេះតាមខ្លួន ។ ចំណែកនិយោជក របស់ពួកគេមិនត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ ដោយសារតែមូលហេតុមិនបានសំរបសំរួលអោយពួកគេចុះឈ្មោះ ដើម្បីទទួលបានលិខិតអនុញ្ញាតអោយធ្វើការងារ ឬ ដកហូតលិខិតអនុញ្ញាតអោយធ្វើការងាររបស់ជនចំណាកស្រុកឡើយ ។

www.mekongmigration.org

**MMN Secretariat**
Hong Kong Office
info@mekongmigration.org
c/o Asian Migrant Centre, Flat 6, 13/F, Block A, Fuk Keung Industrial Building, 66-68 Tong Mi Road, Prince Edward, Kowloon, Hong Kong
Chiang Mai Office
advocacy@mekongmigration.org
c/o MAP Foundation, 63/31 Moo 8, U-mong, Soi 4 (P.O. Box 153 Chiang Mai University 50200) , Thailand

ដូច្នេះហើយ ខណៈពេលដែលជនចំណាកស្រុកយល់ថា ពួកគេត្រូវតែគោរពតាមច្បាប់នៃប្រទេសទទួលនោះ ហើយក៏វាជាការលំបាកផងដែរ សំរាប់ជនចំណាកស្រុកគោរពនៅច្បាប់ទាំងនោះ នៅពេលដែលថៅកែរបស់ពួកគេមិនបានគោរពច្បាប់នោះ ។

## លុបបំបាត់ការហាមប្រាមនានា ដែលធ្វើអោយជនចំណាកស្រុកធ្លាក់ក្នុងលក្ខខណ្ឌ ដែលរំលោភបំពាន និងកេងប្រវញ្ច័ និងបណ្តាលអោយជនចំណាកស្រុកងាយប្រឈមមុខនៅនិងការឃាត់ខ្លួន ឃុំខ្លួន និងការចាប់ខ្លួនបញ្ជូនមកវិញ

ប្រពន្ធ័លិខិតអនុញ្ញាតអោយធ្វើការងារបានបង្កើត និងចាប់បង្ខំអោយជនចំណាកពឹងផ្អែកទាំងស្រុងទៅលើថៅកែនៅក្នុងករីតមួយដែលមានលក្ខណះមិនធម្មតា ហើយដែលបណ្តាលអោយជនចំណាកស្រុកមិនត្រឹមតែពឹងផ្អែកលើថៅកែរបស់គេចំពោះរឿងការងារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបញ្ហានៃការស្នាក់នៅ ម្ហូបអាហារ និងស្ថានភាពអន្តោប្រវេសន៏របស់ពួកគេផងដែរ ។ ការហាមប្រាមកាន់តែច្រើនឡើង១ លើជនចំណាកស្រុក បានធ្វើអោយចំនួននៃអំពើហិង្សាប្រព្រឹត្តឡើង លើជនចំណាកស្រុកកាន់តែច្រើនឡើង១ ។ ដូច្នេះហើយ ការឃាត់ខ្លួន ការឃុំខ្លួន និងការចាប់បញ្ជូន ជនចំណាកស្រុក ត្រលប់មកវិញមានការកើនឡើងជាលំដាប់ផងដែរ ។ ការហាមប្រាមទាំងនេះ បានជំរុញកាន់តែខ្លាំងឡើង នូវអតុល្យភាពនៃអំណាចរវាង ថៅកែ និង កម្មករ ហើយដែលជាមូលហេតុធ្វើអោយថៅកែអាចទាញយកផលប្រយោជន៏ដើម្បីធ្វើការរំលោភបំពាន ឬ កេងប្រវញ្ច័លើកម្មករចំណាកស្រុក ។

ជារឿយ១ លក្ខខណ្ឌការងារ ដែលមានលក្ខណះកេងប្រវញ្ច័ និង រំលោភបំពាន បានជំរុញជនចំណាកស្រុកធ្លាក់ចូលទៅក្នុងស្ថានភាពមួយ ដែលមានលក្ខណៈមិនស្របច្បាប់ ដែលធ្វើអោយជនចំណាកស្រុកកាន់តែងាយប្រឈមមុខទៅនិង ការឃាត់ខ្លួន ការឃុំខ្លួន និងការចាប់បញ្ជូនត្រលប់មកវិញ ។ ជាមួយគ្នានេះផងដែរ ប្រសិនបើជនចំណាកស្រុកចង់គេចចេញពីស្ថានភាពទាំងនេះ និងចង់ផ្លាស់ប្តូរថៅកែរបស់គេនោះ ពួកគេនឹងបាត់បង់នូវស្ថានភាពស្របច្បាប់ ហើយប្រឈមមុខទៅនិងការឃាត់ខ្លួន ។ នៅពេលដែលជនចំណាកស្រុកព្យាយាមធ្វើការចរចារ ពីលក្ខខណ្ឌការងារមួយ ដែលមានលក្ខណៈយុត្តិធមិនោះ ថៅកែរបស់ពួកគេនឹងបញ្ឈប់ការងារ ហើយបន្ទាប់មកលិខិតអនុញ្ញាតអោយធ្វើការងារ របស់ពួកគេនឹងត្រូវដកហូត ។ មានករណីផ្សេង១ទៀត ដែលជនចំណាកស្រុកដែលបានចុះបញ្ជី ក៏ត្រូវបានគេឃាត់ខ្លួនផងដែរ នៅពេលដែលថៅកែរបស់ ពួកគេ បានដកហូតនូវលិខិតអនុញ្ញាតអោយធ្វើការងាររបស់ពួកគេ ។



**MMN Secretariat**
Hong Kong Office
info@mekongmigration.org
c/o Asian Migrant Centre, Flat 6, 13/F, Block A, Fuk Keung Industrial Building, 66-68 Tong Mi Road, Prince Edward, Kowloon, Hong Kong
Chiang Mai Office
advocacy@mekongmigration.org
c/o MAP Foundation, 63/31 Moo 8, U-mong, Soi 4 (P.O. Box 153 Chiang Mai University 50200) , Thailand

ការហាមប្រាមផ្សេងទៀត ដែលរបាយការណ៍ បានលើកយកមកបង្ហាញនោះគឺការហាមប្រាមនូវក្នុការធ្វើដំណើរ ចំពោះអ្នកទាំងឡាយណាដែលអាចចុះបញ្ជីបាន នៅក្នុងកំឡុងពេលនៃការចុះបញ្ជី និងការជួបជុំគ្នាផងដែរ ។ ដោយគ្មានលទ្ធភាពនៅ ក្នុងការអនុវត្តន៏នូវសិទ្ធិជាមូលដ្ឋាននេះ បានធ្វើអោយជនចំណាកស្រុកកាន់តែមិនអាចគេចចេញ ពីការប្រឈមមុខតែច្រើនឡើងនៅក្នុងការឃាត់ខ្លួន ឃុំខ្លួន និងការចាប់បញ្ជូនត្រលប់មកវិញ ។

របាយការនេះក៏លើកឡើង ពីលទ្ធភាពនៃការបង្កើត សេវាកម្មច្រកចេញចូលតែមួយ សំរាប់ជនចំណាកស្រុកទាំងមានឯកសារ និងមិនមានឯកសារ នៅទីកន្លែងបំរើការងារ ជាសេវាកម្មចំលាស់មួយ ដើម្បីដាក់អោយប្រើប្រាស់នូវវិធានការនៃការអនុវត្តិដែលមានលក្ខណះអាក្រក់ ។

## <u>ការកែប្រែនូវនីតិវិធីនៅក្នុងការឃាត់ខ្លួន ការឃុំខ្លួន និងការចាប់បញ្ជូនត្រលប់មកវិញ ដើម្បីធ្វើអោយនីតិវិធីទាំងនោះ មានលក្ខណៈមនុស្សធម៌ តម្លាភាព និងស្ថិតនៅក្រោមបញ្ញត្តិនៃច្បាប់</u>

មានជនចំណាកស្រុកជាច្រើន បានរាយការណ៏ថា ពួកគេអាចជាកម្មវត្ថុ នៃឃាត់ខ្លួននៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ហើយពួកគេមានលទ្ធភាពតិចតួចណាស់ដើម្បីការពារខ្លួនរបស់ពួកគេពីការឃាត់ខ្លួន ។ ការឃាត់ខ្លួនដែលមានលក្ខណៈព្រាវៗ ហើយគ្រប់ពេលវេលា និងគ្រប់ទីកន្លែងនោះ មានន័យថា ជីវិតរបស់ពួកគេប្រឈមមុខនិងភាពភ័យខ្លាច និង អសន្តិសុខគ្រប់ពេលវេលា ។ ជាមួយគ្នានេះផងដែរ ការអនុវត្តន៏ច្បាប់ ដែលមានលក្ខណៈមិនសមស្រប បានគំរាមកំហែង ដល់ទំនុកចិត្តរបស់ជនចំណាកស្រុកនៅក្នុងប្រពន្ធ័ច្បាប់ ហើយដែលបណ្តាលអោយមាននូវបញ្ហាមិនសប្បាយចិត្ត និងភាពទោមនស្សកើតមានឡើង ។ មានករណីជាច្រើន នីតិវិធីនៃការឃាត់ខ្លួន មិនបានគោរពទៅតាមសេចក្តីថ្លៃថ្នូរ និងសុវត្ថិភាពរបស់ជនចំណាកស្រុកផងដែរ ។

*" ពួកយើង ត្រូវបានគេឃាត់ខ្លួន នៅទីកន្លែងបំរើការងារ មានមន្ត្រីប៉ូលីស ចំនួន ១២ នាក់ ដែលរួមមាន ប៉ូលីសជាស្ត្រីចំនួន ០២ នាក់ ។ ពួកគេបានស្រែកថា ប្រសិនបើមាននណាម្នាក់ចង់រត់ ពួកគេនឹងបាញ់ ។ មានមនុស្សម្នាក់បានលោតចូលអូ ហើយរត់គេច ប៉ុន្តែត្រូវបានចាប់យកចេញពីអូវិញ ។ ប៉ូលីសបានទាញគាត់ចេញ ហើយគ្រៀកករគាត់ ហើយបញ្ជូនគាត់ត្រលប់មកវិញ ..................." ។ ( កម្មករភូមារដែលបំរើការងារនៅ មេសត)*


**MMN Secretariat**
Hong Kong Office
info@mekongmigration.org
c/o Asian Migrant Centre, Flat 6, 13/F, Block A, Fuk Keung Industrial Building, 66-68 Tong Mi Road, Prince Edward, Kowloon, Hong Kong
Chiang Mai Office
advocacy@mekongmigration.org
c/o MAP Foundation, 63/31 Moo 8, U-mong, Soi 4 (P.O. Box 153 Chiang Mai University 50200) , Thailand

ជនចំណាកស្រុកកម្ពុជាដែលត្រូវបានសំភាសន៏នៅខេត្តរ៉ាយ៉ង ប្រទេសថៃ បានរាយការណ៏ ថា ភាគច្រើននៃការឃាត់ខ្លួនកម្មករនេសាទ ធ្វើឡើងនៅកណ្តាលយប់ ។ ជាមួយគ្នានេះផងដែរ អ្នកសុំទានជនជាតិកម្ពុជានៅក្នុងទីក្រុងហូជីមិញបានរាយការណ៏ផងដែរថា ការឃាត់ខ្លួនគឺធ្វើឡើងនៅពេលយប់ ។ ជាមួយនិងបញ្ហានៃការឃាត់ខ្លួនកាន់តែកើនឡើងនេះ បណ្តាញជនចំណាកស្រុកមេគង្គ សំណូមពរដល់បណ្តារដ្ឋាភិបាល និងអាជ្ញាធរនានានៅក្នុងតំបន់អោយបញ្ឈប់នូវការអនុវត្តន៏នៃការឃាត់ខ្លួននៅពេលយប់ និង ការឆ្មក់ចូលនៅពេលទៀបភ្លឺ ។

នៅក្នុងករណីផ្សេងៗទៀត ការឃាត់ខ្លួនជនចំណាកស្រុក ដែលចូលមកដោយខុសច្បាប់ ត្រូវបានគេប្រើប្រាស់ក្នុងការឆែកឆេរស្វែងរកគ្រឿងញៀនផងដែរ ។ ស្ត្រីជនជាតិ សានម្នាក់បានប្រាប់ថា នៅពេលដែលពួកគេត្រូវបានឃាត់ខ្លួនដោយទាហ៊ានថៃ នៅតាមផ្លូវដែលគេធ្វើដំណើរចូលក្នុងប្រទេសថៃ នៅតាមច្រកព្រំដែនលួចលាក់រវាងរដ្ឋសាន និងប្រទេសថៃ នៅក្នុងតំបន់ ណុង អុក ។ *" មានកូនខ្ទមដ៏តូចមួយ ដែលយើងត្រូវតែចូលទៅក្នុងបន្ទប់នោះម្តងម្នាក់ ៗ ពួកយើងមិនចង់ដោះខោអាវ ជាពិសេសខោអាវក្នុងទេ ប៉ុន្តែពួកយើងត្រូវគេបង្ខំអោយដោះខោអាវចេញ "* ការឆែកឆេរលើដងខ្លួនរបស់ជនចំណាកស្រុកជាស្ត្រី នៅទីកន្លែងដាច់ដោយឡែកពីគេដោយមន្ត្រីជាបុរសនោះ វារំលោភទៅលើបូរណភាពបុគ្គលរបស់ ស្ត្រី ហើយអាចផ្តល់ឱកាសអោយមានការបៀបបៀនផ្លូវភេទកាន់តែច្រើនឡើងថែមទៀត ។

លក្ខខណ្ឌ និងរយៈពេលឃុំខ្លួនមានលក្ខណះខុសគ្នា ពីកន្លែងមួយទៅកន្លែងមួយទៀត ដោយគ្មានការពន្យល់ជាក់លាក់ ណាមួយឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ ជនចំណាកស្រុកទាំងអស់បាននិយាយថា ពួកគេបានរអ៊ូរទាំថា ពួកគេមិនត្រូវបានគេផ្តល់ព័ត៌មានពីនីតិវិធីច្បាប់ ដែលពាក់ពន្ធ័ទៅនិងការឃុំខ្លួនរបស់ពួកគេឡើយ ដែលរួមបញ្ចូលទាំងពេលវេលានៃការឃុំខ្លួនផងដែរ ។ មានជនចំណាកស្រុកខ្លះបាននិយាយពីបទពិសោធន៏ផ្នែកផ្លូវចិត្តដែលពួកគេបានជួបប្រទះក្នុងកំលុងពេលនៃការឃុំខ្លួនផងដែរ ។

*" ពេលដែលខ្ញុំនៅក្នុងបន្ទប់ឃុំខ្លួន របស់ប៉ូលីសនៅក្នុងតំបន់ មេសត ខ្ញុំបានឃើញប៉ូលីស និង ឆ្កែរបស់ប៉ូលីស ( គ្រាមភាសារបស់ជនជាតិភូមារ ឆ្កែរបស់ប៉ូលីស មានន័យថាអ្នកបកប្រែអោយប៉ូលីស ) បានទិញស្រា វីស្គី ដោយយកលុយរបស់ជនដែលជាប់ឃុំឃាំង ។ នៅពេលដែលពួកគេស្រវឹងពួកគេបានប្រើប្រាស់ភាសាអសុរសទៅលើក្មេងស្រីដែលជាប់ក្នុងបន្ទប់ឃុំខ្លួន ។ នៅពេលខ្លះពួកគេបានយកស្ត្រីនោះចេញពីបន្ទប់ឃុំឃាំង ហើយធ្វើការឆែកឆេលើដងខ្លួនក្មេងស្រីទាំងនោះដោយនិយាយថា គេឆែកឆេរកថ្នាំ អំហ្វេតាមីន ។ ប្រសិនបើបុរស តវ៉ា ពួកគេនឹងត្រូវប៉ូលីសទាត់ ហើយយកទៅឃុំនៅបន្ទប់ឃុំឃាំងផ្សេង ដែលជាទីកន្លែងដែលពួកគេត្រូវបានឃុំខ្លួនរយៈពេល ពីរ ទៅបី ខែដោយគ្មានការកត់ត្រា" ។*



**MMN Secretariat**
Hong Kong Office
info@mekongmigration.org
c/o Asian Migrant Centre, Flat 6, 13/F, Block A, Fuk Keung Industrial Building, 66-68 Tong Mi Road, Prince Edward, Kowloon, Hong Kong
Chiang Mai Office
advocacy@mekongmigration.org
c/o MAP Foundation, 63/31 Moo 8, U-mong, Soi 4 (P.O. Box 153 Chiang Mai University 50200) , Thailand

ក្នុងកំឡុងពេលចាប់បញ្ជូនត្រលប់មកវិញ មានជនចំណាកស្រុកខ្លះបានរាយការណ៍ថា ពួកគត្រូវបានគេប្រមូលជាក្រុម ហើយដាក់ចូលទៅក្នុងឡានចាស់ ដោយមិនបានផ្តល់ម្ហូបអាហារ ទឹក និងមិនអោយបន្ទោបង់នៅតាមផ្លូវធ្វើដំណើរ ឡើយ ហើយជាទូទៅ ពួកគេត្រូវទទួលនូវការប្រព្រឹត្ត លើពួកគេដោយគ្មានសេចក្តីថ្លៃថ្នូរ ។ នៅក្នុងប្រទេសកម្ពុជា និងឡាវ ជនចំណាកស្រុក ត្រូវតែទទួលការពិន័យ ឬ ការផ្តន្ទាទោសអោយធ្វើការងារណាមួយ អោយមន្ត្រីប៉ូលីសអន្តោប្រវេសន៍ ដោយសារតែពួកគេបានចាកចេញដោយខុសច្បាប់ មុននឹងពួកគេអាចត្រលប់ទៅផ្ទះវិញ ។ ជនចំណាកស្រុកមកពីប្រទេសភូមារបានពន្យល់ថា បន្ទាប់ពីពួកគេបានចាប់បញ្ជូនត្រលប់ទៅភូមាវិញ ពួកបានត្រលប់មកប្រទេសថៃវិញភ្លាម១ដែរ ។

របាយការបាន រកឃើញ នៅកង្វះខាតនីតិវិធីមួយ ដែលមានលក្ខណះស្តង់ដារ ជាលទ្ធផលធ្វើអោយ ជនចំណាកស្រុកមានអារម្មណ៍គ្មានអំណាចដើម្បីទាមទារនូវការប្រព្រឹត្តឡើងចំពោះពួកគេ ។ ជនចំណាកស្រុកក៏មានផលវិបាកផងដែរ ដើម្បីដឹងពីសិទ្ធិរបស់គេ ដែលត្រូវរំលោភបំពាន ដោយសារតែពួកគេមិនបានដឹងថាតើស្តង់ដារអ្វី ដែលនឹងត្រូវបានគេប្រើប្រាស់ឡើង ។ សិទ្ធិរបស់ជនចំណាកស្រុក មិនត្រូវបានទទួលបានការគោរពជា ផ្នែកមួយនៃសិទ្ធដែលមិនអាចផ្លាស់ប្តូរបានឡើយ ប៉ុន្តែវាបានប្រែប្រួលរហូតទៅតាមគោលនយោបាយនិងអំណាចឆន្ទានុសិទ្ធិរបស់អាជ្ញាធរ ។ ហើយជាលទ្ធផលថៅកែ និងបុគ្គលផ្សេង១ទៀត មានជំនឿ ក្នុងការគាំទ្រច្បាប់ ដើម្បីបន្តរប្រើប្រាស់នូវភាពចន្លោះ ប្រហោងនៃច្បាប់នោះ ក្នុងការទាញយកផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពីការចំណាយរបស់ជនចំណាកស្រុក ។

*This executive summary is available in the following languages:*

*Burmese;*
*Cambodian (Khmer);*
*Chinese;*
*Laotian;*
*Thai; and*
*Vietnamese.*

*In case of any inconsistencies, please refer to the English text.*

**www.mekongmigration.org**

**MMN Secretariat**
Hong Kong Office
info@mekongmigration.org
c/o Asian Migrant Centre, Flat 6, 13/F, Block A, Fuk Keung Industrial Building, 66-68 Tong Mi Road, Prince Edward, Kowloon, Hong Kong
Chiang Mai Office
advocacy@mekongmigration.org
c/o MAP Foundation, 63/31 Moo 8, U-mong, Soi 4 (P.O. Box 153 Chiang Mai University 50200) , Thailand